**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅ
# នៃគណៈកម្មាធិការជាតិស្នារតីចងចាំនៃពិភពលោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតឡើងនូវគណៈកម្មាធិការជាតិស្មារតីចងចាំនៃពិភពលោក ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ស.ព.** ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីការពារ និងអភិរក្សបេតិកភណ្ឌឯកសារនៅកម្ពុជាក្នុងក្របខ័ណ្ឌអន្តរជាតិ និងគោលបំណងនៃកម្មវិធីស្មារតីចងចាំនៃពិភពលោករបស់អង្គការយូណេស្កូ។

### ជំពូកទី២
### សមាសភាព

**មាត្រា២ .-**

**គ.ជ.ស.ព.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| - តំណាងគណៈកម្មការជាតិយូណេស្កូកម្ពុជា | អនុប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងធម្មការនិងសាសនា | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក | សមាជិក |
| - តំណាងរាជបណ្ឌិត្យសភាកម្ពុជា | សមាជិក |
| - ឥស្សរជនដែលមានចំណេះដឹងជ្រៅជ្រះផ្នែកបេតិកភណ្ឌវប្បធម៌ | សមាជិក |
| - តំណាងបណ្ណសារដ្ឋានជាតិកម្ពុជា | សមាជិក |
| - តំណាងបណ្ណាល័យជាតិ | សមាជិក |
| - តំណាងសារមន្ទីរជាតិ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ**គ.ជ.ស.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ច

**មាត្រា៣ .-**

**គ.ជ.ស.ព.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- តំណាងឲ្យព្រះរាជាណាចក្រកម្ពុជាក្នុងការប្រជុំថ្នាក់តំបន់និងថ្នាក់អន្តរជាតិ ដែលទាក់ទងនឹងកម្មវិធីស្មារតីចងចាំនៃពិភពលោករបស់អង្គការយូណេស្កូ
- បង្កើតនិងគ្រប់គ្រងបញ្ជីស្មារតីចងចាំនៃពិភពលោកថ្នាក់ជាតិរបស់កម្ពុជា ដោយលើកទឹកចិត្តទទួលយក និងវាយតម្លៃលើការស្នើសុំដាក់បញ្ចូលបេតិកភណ្ឌឯកសារនៅក្នុងបញ្ជីនេះ
- សហការនិងសម្របសម្រួលជាមួយគណៈកម្មការជាតិយូណេស្កូកម្ពុជា ដើម្បីស្នើសុំដាក់បញ្ចូលបេតិកភណ្ឌឯកសាររបស់កម្ពុជាទៅក្នុងបញ្ជីស្មារតីចងចាំនៃពិភពលោកថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក និងថ្នាក់សកលលោក
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការស្មារតីចងចាំនៃពិភពលោកថ្នាក់តំបន់អាស៊ីប៉ា-ស៊ីហ្វិក និងបោះឆ្នោតក្នុងនាមជាសមាជិកនៃគណៈកម្មាធិការនេះ
- សហការជិតស្និទ្ធជាមួយស្ថាប័នជាតិ អន្តរជាតិ និងបុគ្គលផ្សេងៗទៀតដែលពាក់ព័ន្ធ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការការពារនិងការអភិរក្សបេតិកភណ្ឌឯកសារ និងជំរុញការចុះបញ្ជីស្មារតីចងចាំនៃពិភពលោកថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកលលោក
- បង្កើនការយល់ដឹងជាសាធារណៈនិងផ្ដល់ឱកាសចូលទៅប្រើប្រាស់បេតិកភណ្ឌឯកសារ ព្រមទាំងផ្សព្វផ្សាយកម្មវិធីស្មារតីចងចាំនៃពិភពលោកនៅក្នុងប្រទេស
- បំពេញបេសកកម្មផ្សេងទៀតក្នុងក្របខ័ណ្ឌនិងគោលបំណងនៃកម្មវិធីស្មារតីចងចាំនៃពិភពលោករបស់អង្គការយូណេស្កូ ដូចមានចែងនៅក្នុងគោលការណ៍ណែនាំទូទៅរបស់ស្មារតីចងចាំនៃពិភពលោក
- ធ្វើរបាយការណ៍ប្រចាំឆ្នាំជូនទៅលេខាធិការដ្ឋានស្មារតីចងចាំនៃពិភពលោកថ្នាក់សកលលោក ថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក និងចម្លងជូនគណៈកម្មការជាតិយូណេស្កូកម្ពុជា
- ពិគ្រោះយោបល់ជាមួយស្ថាប័ននិងអង្គភាពដទៃមួយចំនួនទៀតដែលចាំបាច់
- បំពេញភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូនក្នុងក្របខ័ណ្ឌរបស់ស្មារតីចងចាំថ្នាក់ជាតិ ឬថ្នាក់តំបន់ ឬថ្នាក់សកលលោក។

## ជំពូកទី៤
## ការប្រព្រឹត្តទៅ

**មាត្រា៤ .-**

**គ.ជ.ស.ព.** ត្រូវប្រជុំសាមញ្ញយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំ និងវិសាមញ្ញតាមការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធានដើម្បីដឹកនាំកិច្ចប្រជុំនំនួស។

**គ.ជ.ស.ព.** មានសិទ្ធិអញ្ជើញតំណាងការិយាល័យយូណេស្កូភ្នំពេញ ឥស្សរជន ឬអ្នកជំនាញការជាតិនិងអន្តរជាតិក្នុងផ្នែកអភិរក្សបេតិកភណ្ឌឯកសារ ព្រមទាំងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមកចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន។

**មាត្រា៥ .-**

បែបបទនិងនីតិវិធីការងារនៃ**គ.ជ.ស.ព.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងនៃ**គ.ជ.ស.ព.**។

**មាត្រា៦ .-**

**គ.ជ.ស.ព.**មានសិទ្ធិបង្កើតគណៈកម្មការ អនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដើម្បីជួយបំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

សមាសភាពនិងតួនាទីភារកិច្ចរបស់គណៈកម្មការ អនុគណៈកម្មការ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.ស.ព.**។

**មាត្រា៧ .-**

**គ.ជ.ស.ព.**មានលេខាធិការដ្ឋានមួយ ជាសេនាធិការដែលមានទីតាំងនៅទីស្តីការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

លេខាធិការដ្ឋាននៃ**គ.ជ.ស.ព.** ត្រូវដឹកនាំដោយប្រធាន១(មួយ)រូបនិងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

ប្រធាននិងអនុប្រធានលេខាធិការដ្ឋាននៃ **គ.ជ.ស.ព.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

លេខាធិការដ្ឋាននេះមានមន្ត្រីជំនាញមកពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃ**គ.ជ.ស.ព.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលជាប្រធាន**គ.ជ.ស.ព.**។

**មាត្រា៨ .-**

**គ.ជ.ស.ព.** មានសិទ្ធិប្រើនិមិត្តសញ្ញារបស់ស្មារតីចងចាំនៃពិភពលោក បន្ទាប់ពីទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីលេខាធិការដ្ឋានអន្តរជាតិស្មារតីចងចាំនៃពិភពលោក តាមរយៈគណៈកម្មការជាតិយូណេស្កូកម្ពុជា។

**គ.ជ.ស.ព.** មានសិទ្ធិប្រើត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

## ជំពូកទី៥
## ប្រភពធនធាននិងមូលនិធិ

**មាត្រា៩ .-**

ការចំណាយសម្រាប់ដំណើរការរបស់**គ.ជ.ស.ព.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

**គ.ជ.ស.ព.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**ជំពូកទី៦**
**អវសានប្បញ្ញត្តិ**

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ